# អនុស្សរណៈនៃការយោគយល់គ្នា
# រវាង
# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ
# និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# ស្តីពី
# កិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស
# និងការជួយជនរងគ្រោះដោយសារការជួញដូរ

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (ដែលតទៅនេះកំណត់ថាជា "រដ្ឋភាគី")

ដោយមានបំណងពង្រឹងបន្ថែមទៀតនូវចំណងមិត្តភាពរវាងប្រទេសទាំងពីរ និងបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី ស្តីពីការបង្ក្រាបការជួញដូរមនុស្ស ។

ដោយទទួលស្គាល់ថា ការជួញដូរមនុស្សគឺជាការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ហើយជាការជាន់ឈ្លីយ៉ាងធ្ងន់ទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។

ដោយមានការព្រួយបារម្ភជាខ្លាំងថា ការជួញដូរមនុស្សជះឥទ្ធិពលជាអវិជ្ជមានទៅលើការរីកចម្រើននៃសរីរាង្គបុគ្គល គំនិតស្មារតី ទឹកចិត្ត សីលធម៌ និងធ្វើឲ្យខូចប្រយោជន៍ដល់របៀបរៀបរយ និងតម្លៃនៃសង្គម។

ដោយយល់ឃើញថា ក្រុម និងអង្គការឧក្រិដ្ឋកម្មឆ្លងដែន មានការទាក់ទិនយ៉ាងសកម្មទៅនឹងការជួញដូរមនុស្ស ជាពិសេសកុមារ និងស្ត្រី ហើយឧក្រិដ្ឋកម្មដែលមានការចាត់តាំង និងមានលក្ខណៈឆ្លងដែនបែបនេះ មិនគ្រាន់តែជះឥទ្ធិពលអាក្រក់ដល់ប្រទេសថៃនិងប្រទេសកម្ពុជាប៉ុណ្ណោះទេ ថែមទាំងជះឥទ្ធិពលអាក្រក់ដល់បណ្តាប្រទេសក្នុងតំបន់ និងពិភពលោកទាំងមូល។

ដោយធ្វើការអះអាងថា រដ្ឋភាគីមានការព្រួយបារម្ភរួមគ្នាចំពោះការជួញដូរមនុស្សដែលមានលក្ខណៈឆ្លងដែន ដូចដែលបានថ្លែងនៅក្នុងសេចក្តីប្រកាសនៅទីក្រុងបាងកក ស្តីពីទេសន្តប្រវេសន៍មិនប្រក្រតីដែលបានពិភាក្សានៅក្នុងសន្និសីទអន្តរជាតិស្តីពីទេសន្តប្រវេសន៍ "សំដៅឱ្យមានកិច្ចសហប្រតិបត្តិការតំបន់ស្តីពីទេសន្តប្រវេសន៍មិនប្រក្រតី ឬ ទេសន្តប្រវេសន៍គ្មានឯកសារត្រឹមត្រូវ" ដែលបានប្រព្រឹត្តិទៅនៅថ្ងៃទី២១ ដល់ ២៣ ខែមេសា ឆ្នាំ១៩៩៩ ក្នុងទីក្រុងបាងកក និង "សន្និសីទរដ្ឋមន្ត្រីថ្នាក់តំបន់ស្តីពីការរត់ពន្ធ និងការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនដែលជាប់ទាក់ទង" ដែលបានប្រព្រឹត្តិធ្វើនៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី២៦ ដល់ ២៨ ខែកុម្ភៈ ឆ្នាំ២០០២ សេចក្តីថ្លែងការណ៍របស់អាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលត្រូវបានអនុម័តនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០៤ នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សេចក្តីថ្លែងការណ៍របស់អាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិកម្មករទេសន្តប្រវេសន៍ ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៧ នៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងនឹងការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់មេគង្គ ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៩ ខែតុលា ឆ្នាំ ២០០៤ នៅទីក្រុងយ៉ង់ហ្គូន ប្រទេសមីយ៉ាន់ម៉ា សេចក្តីថ្លែងការណ៍រួមរបស់គំនិតផ្តួចផ្តើមសម្របសម្រួលថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់មេគង្គប្រឆាំងនឹងអំពើជួញដូរមនុស្ស ដែលត្រូវបានចុះហត្ថលេខា នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ នៅទីក្រុង

S. Khongk

[signature]

ប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន គោលការណ៍ណែនាំសម្រាប់ការការពារជនរងគ្រោះដោយសារការជួញដូរ នៅក្នុងមហាអនុតំបន់មេគង្គ នៅថ្ងៃទី២២ ដល់២៤ ខែសីហា ឆ្នាំ២០០៧ និងសេចក្តីថ្លែងការណ៍រួមរបស់ខមមីតលើកទី២ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម។

**ដោយរំលឹកឡើងវិញ** អំពីកំណត់ហេតុដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ក្នុងសម័យប្រជុំលើកទី៣ នៃគណៈកម្មការរួមសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ និងព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឡើងនៅខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជាកាលពីថ្ងៃទី៣១ ខែមករា ដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០០ ដែលក្នុងនោះបានបញ្ជាក់ពីការបង្កើនកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ស្តីពីការបង្ក្រាបការជួញដូរមនុស្សឆ្លងដែន ជាពិសេសការជួញដូរស្ត្រី និងកុមារ កំណត់ហេតុនៃកិច្ចប្រជុំនៅក្រុងបាងកក ថ្ងៃទី២៧-២៩ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីគោលការណ៍ណែនាំសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម គោលការណ៍ណែនាំសម្រាប់កិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងថៃ ស្តីពីនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌនៃបទឧក្រិដ្ឋទាក់ទងនឹងការជួញដូរមនុស្សដែលបានធ្វើនៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២១ខែ កក្កដា ឆ្នាំ២០០៦ និងកំណត់ហេតុកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៥ នៅខេត្តសៀមរាប នៅថ្ងៃទី២៤ ដល់ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១២ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាសម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងការប្រើប្រាស់កម្លាំងពលកម្មរវាងក្រសួងការងារនៃព្រះរាជាណាចក្រថៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា ។

**ដោយយោង** មាត្រាដែលជាប់ទាក់ទងនឹងការជួញដូរមនុស្ស ដូចដែលបានចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ពិធីសារអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង អនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារបន្ថែមស្តីពីការលក់ដូរកុមារ ពេស្យាចារកុមារ និង រូបអាសអាភាសកុមារ និងពិធីសារបន្ថែមស្តីពីការពាក់ព័ន្ធកុមារនៅក្នុងជម្លោះប្រដាប់អាវុធ អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៨២ ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ២៩ ស្តីពីពលកម្មដោយបង្ខំ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងស្ត្រី និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិផ្សេងទៀត ដែលភាគីទាំងពីរបានផ្តល់សច្ចាប័ន ឬចូលជាសមាជិក។

**ដោយជឿជាក់ថា** ការបង្ក្រាបបទឧក្រិដ្ឋជួញដូរមនុស្ស តាមរយៈកិច្ចសហប្រតិបត្តិការទៅវិញទៅមកក្នុងការអនុវត្តន៍ច្បាប់ និងក្នុងនីតិវិធីព្រហ្មទណ្ឌ គឺជាវិធានការដ៏មានប្រសិទ្ធភាពក្នុងការធានាយុត្តិធម៌ប្រឆាំងនឹងការជួញដូរមនុស្ស។

ដោយធ្វើការសន្យាថា រដ្ឋភាគីនឹងធ្វើសហប្រតិបត្តិការយ៉ាងស្មោះស្ម័គ្រក្នុងការលុបបំបាត់ការជួញដូរមនុស្ស ព្រមទាំងការពារ និងជួយដល់ជនរងគ្រោះ។

បានព្រមព្រៀងគ្នាដូចតទៅ៖

## ផ្នែកទី១: វិសាលភាពនៃអនុស្សរណៈ នៃការយោគយល់គ្នា

**ប្រការ១៖**

អនុស្សរណៈនៃការយោគយល់នេះត្រូវអនុវត្តចំពោះការជួញដូរមនុស្ស ដូចមាននិយមន័យក្នុងប្រការ២ នៃអនុស្សរណៈនេះ។

## ផ្នែកទី២: និយមន័យ

**ប្រការ២៖**

ក្នុងការអនុវត្តន៍អនុស្សរណៈ នៃការយោគយល់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

ក. "ការជួញដូរមនុស្ស" មានន័យថា៖ ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលមនុស្សដោយប្រើប្រាស់មធ្យោបាយគម្រាមកំហែង ការប្រើប្រាស់កម្លាំង ឬទម្រង់ផ្សេងៗនៃការបង្ខិតបង្ខំ ការចាប់ពង្រត់ ការឆបោក ការបញ្ឆោត ការរំលោភអំណាច ឬការរំលោភលើស្ថានភាពដែលងាយរងគ្រោះ ការប្រគល់ឬទទួលប្រាក់យកកម្រៃ ឬផលប្រយោជន៍ណាមួយដើម្បីទទួលបានការយល់ព្រមពីសំណាក់បុគ្គលណាម្នាក់ ដែលមានអំណាចគ្រប់គ្រងលើបុគ្គលផ្សេងទៀតក្នុងគោលដៅដើម្បីកេងប្រវ័ញ្ច។ ការកេងប្រវ័ញ្ចមានដូចជា ការកេងប្រវ័ញ្ចលើពេស្យាកម្មជនដទៃ ឬទម្រង់ផ្សេងៗទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្ម ឬសេវាដោយបង្ខំ ទាសភាព ឬការអនុវត្តស្រដៀងគ្នានឹងទាសភាព សេវភាព ឬការដកហូតសរីរាង្គណាមួយ។

ខ. ការយល់ព្រមរបស់ជនរងគ្រោះដោយសារអំពើជួញមនុស្សទៅលើការកេងប្រវ័ញ្ច ដែលមានគោលបំណងគិតទុកជាមុនដូចមានរៀបរាប់នៅក្នុងកថាខណ្ឌ (ក) នៃប្រការនេះ នឹងមិនយកជាការបានទេប្រសិនបើមធ្យោបាយណាមួយដែលមានចែងនៅក្នុងកថាខណ្ឌ (ក) នេះ ត្រូវបានប្រើប្រាស់។

គ. ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយក កុមារក្នុងគោលដៅដើម្បីកេងប្រវ័ញ្ចនឹងត្រូវចាត់ទុកថាជា "ជនរងគ្រោះដោយសារការជួញដូរ" បើទោះបីជាករណីនេះមិនមានការប្រើប្រាស់មធ្យោបាយណាមួយដូចមានចែងនៅក្នុងកថាខណ្ឌ (ក) នៃប្រការនេះក៏ដោយ។

ឃ. "កុមារ" មានន័យថាបុគ្គលដែលមានអាយុក្រោម ១៨ឆ្នាំ។

## ផ្នែកទី៣: វិធានការទប់ស្កាត់

**ប្រការ៣៖**

រដ្ឋភាគីត្រូវចាត់វិធានការកែទម្រង់ច្បាប់តាមការចាំបាច់ និងចាត់វិធានការសមស្របផ្សេងៗទៀតដើម្បីធានាថា ក្របខ័ណ្ឌច្បាប់នៅក្នុងយុត្តាធិការរៀងៗខ្លួន ស្របទៅនឹងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ពិធីសារអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង និងលិខិតតូបករណ៍អន្តរជាតិ និងតំបន់ពាក់ព័ន្ធការជួញដូរមនុស្សដទៃទៀត ដែលរដ្ឋភាគីទាំងពីរបានចូលជាសមាជិក។

**ប្រការ៤៖**

រដ្ឋភាគីត្រូវអនុវត្តកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈនានា ដែលតម្រូវរបស់កុមារ ស្ត្រី និងបុរស ដើម្បីបង្កើនឱកាសមានមុខរបរ និងកាត់បន្ថយភាពងាយរងគ្រោះដោយសារការជួញដូរ។

**ប្រការ៥៖**

រដ្ឋភាគីទាំងពីរត្រូវធ្វើការប្រឹងប្រែងដើម្បីទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈវិធានការទប់ស្កាត់ ដូចតទៅ៖

ក. បង្កើនការផ្តល់សេវានិងកិច្ចគាំពារសង្គមដូចជា ជួយរកការងារឱ្យធ្វើ ជួយក្នុងការបង្កើតឱ្យមានចំណូល និងផ្តល់ការថែទាំសុខភាពដល់ប្រជាជនដែលងាយរងគ្រោះដោយសារការជួញដូរ។

ខ. កែលម្អកម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យប្រសើរឡើង ដើម្បីបង្កើនការផ្សារភ្ជាប់ទៅនឹងការអប់រំ និងឱកាសការងារ។

គ. បង្កើនចំណេះដឹង និងការយល់ដឹងដល់សាធារណជន អំពីទេសន្តប្រវេសន៍ដោយសុវត្ថិភាព និងបញ្ហាជួញដូរមនុស្ស ជាពិសេសកុមារ និងស្ត្រីរួមមាន៖

(i) ផ្សព្វផ្សាយព័ត៌មានដល់សាធារណជន អំពីកត្តាប្រថុយប្រថាននៃទេសន្តប្រវេសន៍ និងគ្រោះថ្នាក់ ព្រមទាំងឥទ្ធិពលអវិជ្ជមានផ្សេងៗនៃការជួញដូរមនុស្ស។

(ii) គាំទ្រការបង្កើតឲ្យមានបណ្តាញការពារ និងឃ្លាំមើលសហគមន៍ ជាពិសេសនៅក្នុងតំបន់មានភាពប្រថុយប្រថានខ្ពស់។

(iii) ពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋភាគី និងផ្នែកឯកជននានា ដើម្បីពង្រីកតួនាទីរបស់ពួកគេនៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

## ផ្នែកទី៤: កិច្ចការពារជនរងគ្រោះដោយសារការជួញដូរមនុស្ស

### ប្រការ៦៖

ជនដែលត្រូវគេជួញដូរត្រូវបានចាត់ទុកជាជនរងគ្រោះ ហើយមិនមែនជាអ្នករំលោភបំពាន ឬជាជនល្មើសច្បាប់អន្តោប្រវេសន៍ទេ។ ហេតុនេះ៖

ក. ជនដែលត្រូវគេជួញដូរមិនត្រូវបានចោទប្រកាន់ពីបទអន្តោប្រវេសន៍ខុសច្បាប់។

ខ. ជនដែលត្រូវគេជួញដូរ មិនត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលឃុំឃាំងអន្តោប្រវេសន៍ក្នុងពេលរង់ចាំដំណើរការធ្វើមាតុភូមិនិវត្តន៍ជាផ្លូវការ មកកាន់ប្រទេសខ្លួនវិញនោះទេ ប៉ុន្តែពួកគេត្រូវស្ថិតនៅក្នុងការថែទាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (កម្ពុជា) ឬ នាយកដ្ឋានអភិវឌ្ឍន៍ និងសុខុមាលភាពសង្គម (ថៃ) ហើយនៅទីនោះការផ្តល់ជម្រក និងការការពារត្រូវបានផ្តល់ដល់ជនរងគ្រោះទៅតាមគោលនយោបាយរបស់រដ្ឋភាគីនីមួយៗ។

គ. អាជ្ញាធរពាក់ព័ន្ធត្រូវធានាសន្តិសុខដល់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ។

ឃ. ជនរងគ្រោះត្រូវទទួលបានការគាំពារប្រកបដោយមនុស្សធម៌ និងត្រូវបានផ្តល់ឱកាសដើម្បីទាក់ទងជាមួយក្រុមគ្រួសារជិតស្និទ្ធ ដែលអនុវត្តប្រកបដោយសុវត្ថិភាព តាមរយៈដំណើរការនៃការការពារ ការធ្វើមាតុភូមិនិវត្តន៍ និងនៅក្នុងនីតិវិធីតុលាការ។

ង. ជនរងគ្រោះ ជាពិសេសកុមារ ត្រូវទទួលបានសេវា ផ្អែកលើសិទ្ធិជាមូលដ្ឋានសមស្របតាមអាយុ ឆ្លើយតបនឹងយេនឌ័រ ក្នុងអំឡុងពេលដំណើរការថែទាំបណ្តោះអាសន្ន ការធ្វើមាតុភូមិនិវត្តន៍ និងក្នុងនីតិវិធីតុលាការ។

ច. កុមារដែលស្ថិតនៅជាមួយជនរងគ្រោះ ត្រូវមានសិទ្ធិទទួលបានការការពារដោយយោងតាមច្បាប់ជាតិរបស់រដ្ឋភាគីនីមួយៗ។

**ប្រការ៧៖**

រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានាដែលអាចរាប់បញ្ចូលទាំងការកែទម្រង់ច្បាប់ និងជំនួយផ្នែកច្បាប់ ដើម្បីធានាឲ្យមានដំណោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព ចំពោះជនរងគ្រោះដោយសារការជួញដូរដូចតទៅ៖

ក. ជនរងគ្រោះអាចប្តឹងទាមទារមកវិញនូវទ្រព្យសម្បត្តិ និងសម្ភារៈជាប់ខ្លួនដែលគ្មាន វិវាទ ហើយដែលត្រូវបានដកហូត ដោយអាជ្ញាធរពាក់ព័ន្ធ នៅដំណាក់កាលនានានៃដំណើរការផ្លូវច្បាប់។

ខ. ផលនៃបទល្មើសជួញដូរមនុស្ស នឹងត្រូវរឹបអូសរក្សាទុក ហើយត្រូវចាត់ចែងគ្រប់គ្រងទៅច្បាប់របស់ប្រទេសភាគីរៀងៗខ្លួន។

គ. ជនរងគ្រោះអាចប្តឹងទារសំណងពីជនល្មើសនូវការខូចខាតទាំងឡាយ ដែលបង្ក ឡើងដោយការជួញដូរមនុស្ស។

ឃ. ជនរងគ្រោះអាចទាមទារផលកម្រៃពលកម្ម ដែលមិនទាន់បានទទួលពីជនល្មើស។

ង. ជនរងគ្រោះត្រូវទទួលបាននូវការអនុវត្តនីតិវិធីត្រឹមត្រូវតាមផ្លូវច្បាប់ សម្រាប់ការទាមទាររកភាពយុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌ និងការជួសជុលការខូចខាត និងដំណោះស្រាយផ្សេងៗទៀត តាមផ្លូវតុលាការ។

ច. ជនរងគ្រោះត្រូវទទួលបានព័ត៌មាននិងសេវាបកប្រែតាំងពីការទទួលពីដំបូងរហូត ដល់ការធ្វើសមាហរណកម្ម។

**ប្រការ៨៖**

ទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ ដោយមានកិច្ចសហប្រតិបត្តិការសមស្របជាមួយអង្គការមិនមែនរដ្ឋាភិបាល ត្រូវផ្តល់ដល់ជនរងគ្រោះ និងសមាជិកគ្រួសារដែលជិតស្និទ្ធ ប្រសិនបើមាននូវជម្រកប្រកបដោយសុវត្ថិភាព និងការថែទាំសុខភាពដែលឆ្លើយតបនឹងយេនឌ័រ រួមទាំងការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ និងការជួយឧបត្ថម្ភចាំបាច់ផ្សេងៗទៀត សម្រាប់កិច្ចការពាជនរងគ្រោះទាំងនោះ។

## ផ្នែកទី៥: កិច្ចសហប្រតិបត្តិការក្នុងការបង្ក្រាបអំពើជួញដូរមនុស្ស

**ប្រការ៩៖**

ភ្នាក់ងារមានសមត្ថកិច្ចអនុវត្តច្បាប់នៃប្រទេសទាំងពីរ ជាពិសេសនៅតាមព្រំដែន ត្រូវ ធ្វើការដោយមានកិច្ចសហការគ្នាជិតស្និទ្ធ ក្នុងការស្វែងរកឲ្យឃើញនូវការជួញដូរមនុស្សក្នុងស្រុក និង ឆ្លងប្រទេស។

**ប្រការ១០៖**

ក. ដំណើរការអនុវត្តច្បាប់ ត្រូវតែធ្វើឲ្យមានភាពប្រសើរឡើង ដើម្បីប្រយុទ្ធប្រឆាំងនឹង ឧក្រិដ្ឋកម្មជួញដូរមនុស្សឲ្យមានប្រសិទ្ធភាព។

ខ. ត្រូវបង្កើនការស៊ើបអង្កេត និងការចោទប្រកាន់ជនល្មើស និងក្រុមឧក្រិដ្ឋជនទាក់ទងករណីជួញដូរមនុស្ស។

គ. រដ្ឋភាគីត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលជាឯកតោភាគី និងទ្វេភាគីស្តីពីការផ្តន្ទាទោស ច្បាប់ពាក់ព័ន្ធ និងជំនាញស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ការស៊ើបអង្កេត និងការការពារនៅក្នុងករណីជួញដូរ សម្រាប់មន្ត្រីទទួលបន្ទុកអនុវត្តច្បាប់ ឲ្យស្របតាមបទដ្ឋានអន្តរជាតិ។

**ប្រការ១១៖**

ក. រដ្ឋភាគីត្រូវជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី ចំពោះនីតិវិធីតុលាការប្រឆាំងនឹងការជួញមនុស្ស ដូចជាការផ្តន្ទាទោសចំពោះអ្នកជួញដូរឆ្លងដែន ដោយអនុលោមទៅតាមសន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងប្រទេសថៃ និងសន្ធិសញ្ញាអាស៊ានស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌ។

ខ. រដ្ឋភាគីត្រូវចាត់វិធានការជំនួយផ្នែកច្បាប់យ៉ាងទូលំទូលាយបំផុត ទៅវិញទៅមកនៅក្នុងការស៊ើបអង្កេត ការផ្តន្ទាទោស ដំណើរការក្នុងផ្លូវតុលាការចំពោះអំពើជួញដូរមនុស្ស ជាពិសេសលើកុមារ និងស្ត្រី រួមបញ្ចូលទាំងសន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងប្រទេសថៃ ដែលមានស្រាប់។

**ប្រការ១២៖**

នគរបាល នគរបាលយុត្តិធម៌ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតនៃប្រទេសទាំងពីរ ក្នុងករណីដែលអាចត្រូវធ្វើសហប្រតិបត្តិការលើការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងករណីជួញដូរមនុស្ស ដូចជាច្រកជួញដូរ ទីកន្លែងជួញដូរ អត្តសញ្ញាណអ្នកជួញដូរ បណ្តាញនៃការជួញដូរ មធ្យោបាយ វិធីសាស្ត្រនៃការជួញដូរ និងទិន្នន័យអំពីការជួញដូរមនុស្ស។

**ប្រការ១៣៖**

ក. ក្រសួង ទីភ្នាក់ងារ អង្គការ និងយន្តការរបស់ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាលដែលជាប់ពាក់ព័ន្ធរបស់រដ្ឋភាគីទាំងពីរ ត្រូវធ្វើកិច្ចសហប្រតិបត្តិការដើម្បីប្រមូលព័ត៌មាន និងភស្តុតាងទាក់ទងនឹងករណីជួញដូរមនុស្ស។

ខ. ចំពោះកិច្ចសហប្រតិបត្តិការក្រៅផ្លូវការនៅក្នុងការស៊ើបអង្កេត ការទទួលបានព័ត៌មានយោងតាមកថាខណ្ឌខាងលើ ត្រូវបានផ្តល់ជូនយ៉ាងត្រឹមត្រូវដល់មន្ត្រីនគរ បាលមានសមត្ថកិច្ច ការិយាល័យអន្តោប្រវេសន៍ ការិយាល័យព្រះរាជអាជ្ញា ឬដល់អាជ្ញាធរជាប់ពាក់ព័ន្ធដទៃទៀត ដែលចាត់វិធានការផ្នែកច្បាប់ចំពោះករណីជួញដូរមនុស្ស យោងតាមតួនាទីជាប់ពាក់ព័ន្ធ និងនីតិវិធីនៃប្រទេសរៀងខ្លួន ដូចជាការស្រាវជ្រាវរកជនល្មើស ការស៊ើបអង្កេតករណី និងដំណើរនីតិវិធីតុលាការដទៃទៀត។

គ. ភស្តុតាងដែលប្រើនៅក្នុងតុលាការ ត្រូវបានទទួលតាមផ្លូវការទូតយោងតាមច្បាប់ផ្សេងៗនៃរដ្ឋភាគីទាំងពីរ ប្រសិនបើរដ្ឋភាគីទាំងពីរមិនមានបង្កើតសន្ធិសញ្ញាទ្វេភាគី ឬពហុភាគី ដែលចែងអំពីនីតិវិធីផ្សេងៗសម្រាប់ជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងបញ្ហាព្រហ្មទណ្ឌ។

**ប្រការ១៤៖**

ក. នគរបាល នគរបាលយុត្តិធម៌ និងអាជ្ញាធរពាក់ព័ន្ធផ្សេងៗទៀតនៃរដ្ឋភាគីត្រូវចាត់ វិធានការចាំបាច់នានាដើម្បីធានាសុវត្ថិភាពដល់ជនរងគ្រោះ និងសាក្សី ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ នៅក្នុងអំឡុងពេល និងក្រោយពេលនៃដំណើរការរឿងក្តីតាមនីតិវិធីតុលាការ។

ខ. អាជ្ញាធរពាក់ព័ន្ធត្រូវផ្តល់ជំនួយគាំទ្រចាំបាច់ដើម្បីធានាថា ជនរងគ្រោះអាចចូលរួមបានពេញលេញនៅក្នុងនីតិវិធីតុលាការ បន្ទាប់ពីជនរងគ្រោះបានផ្តល់ការយល់ព្រមជាមុន និងដោយមានការគិតគូរទៅលើឧត្តមប្រយោជន៍របស់ពួកគេ។

## ផ្នែកទី៦: ការធ្វើមាតុភូមិនិវត្តន៍

**ប្រការ១៥៖**

ក. រៀបចំសម្របសម្រួលឱ្យមានការកំណត់អត្តសញ្ញាណនិងធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះឱ្យបានឆាប់រហ័ស។

ខ. អាជ្ញាធរទទួលបន្ទុកការធ្វើមាតុភូមិនិវត្តន៍ត្រូវប្រើប្រាស់ផ្លូវការទូត ក្នុងការទំនាក់ទំនង និងជូនព័ត៌មានជាមុនទៅភាគីម្ខាងទៀត ដើម្បីរៀបចំការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ជាពិសេសកុមារ និងស្ត្រី។

គ. ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ជាពិសេសកុមារ និងស្ត្រី ត្រូវរៀបចំឡើងនិងប្រព្រឹត្តទៅក្នុងឧត្តមប្រយោជន៍របស់ពួកគេ រួមមានការការពារសុវត្ថិភាពនិងការគោរពសេចក្តីថ្លៃថ្នូររបស់ពួកគេ។

ឃ. ជនដែលត្រូវគេជួញដូរ ជាពិសេសកុមារ និងស្ត្រីទាំងឡាយដែលត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះដោយសារការជួញដូរ នឹងមិនត្រូវចាប់បញ្ជូនត្រឡប់ឡើយ។ ការធ្វើមាតុភូមិនិវត្តន៍នឹងត្រូវចាត់វិធានការយោងតាមប្រការខាងលើ។

**ប្រការ១៦៖**

ក. រដ្ឋភាគីនីមួយៗត្រូវបង្កើតក្រុមការងារមួយ។ ក្រុមការងាររបស់ភាគីនីមួយៗត្រូវមានស្ថាប័នបង្គោលដើម្បីសហការអនុវត្តសកម្មភាពរួម។

ខ. ក្រុមការងារត្រូវបង្កើតឡើង ដោយមានសមាសភាពពីអាជ្ញាធរមានសមត្ថកិច្ចនានា នៃប្រទេសនីមួយៗ និងដៃគូពាក់ព័ន្ធ។

គ. ក្រុមការងាររបស់រដ្ឋភាគីនីមួយៗ មានភារកិច្ចដូចតទៅ៖

(i) រៀបចំការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ជាពិសេសកុមារ និងស្ត្រី

(ii) អនុវត្តការធ្វើមាតុភូមិនិវត្តន៍ដែលរៀបចំឡើងសម្រាប់ជនរងគ្រោះ ជាពិសេស កុមារ និងស្ត្រី។

(iii) ផ្តល់កិច្ចការពារសន្តិសុខដល់ជនរងគ្រោះ ជាពិសេសកុមារ និងស្ត្រីនៅក្នុងដំណើរការធ្វើមាតុភូមិនិវត្តន៍។

(iv) ខិតខំត្រួតពិនិត្យនិងតាមដានការធ្វើសមាហរណកម្មជនរងគ្រោះដោយយកចិត្តទុកដាក់។

(v) បង្កើតបណ្តាញព័ត៌មានទាក់ទងនឹងការជួញដូរមនុស្សនៅក្នុងចំណោមអាជ្ញាធរអនុវត្តច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងសង្គមស៊ីវិលផង។

## ផ្នែកទី៧: សមាហរណកម្ម

**ប្រការ១៧៖**

ក. រដ្ឋភាគីត្រូវខិតខំធ្វើយ៉ាងណា ឱ្យសម្រេចបាននូវការធ្វើសមាហរណកម្មជនរងគ្រោះដោយសារការជួញដូរ ប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធភាព

ទៅក្នុងក្រុមគ្រួសារ និងសហគមន៍ ទៅតាមករណីសមស្រប ដើម្បីពួកគេទទួលបានឡើងវិញនូវសេចក្ដីថ្លៃថ្នូរ និងសុខុមាលភាព។

ខ. រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានា ដែលឆ្លើយតបនឹងយេនឌ័រដោយផ្អែកទៅលើឧត្ដមប្រយោជន៍របស់ជនរងគ្រោះ ដើម្បីសម្រេចគោលបំណងដូចតទៅ៖

(i) ជនរងគ្រោះដោយសារការជួញដូរនឹងមិនត្រូវទទួលរងនូវការប៉ះទង្គិចស្លាកស្នាមផ្លូវចិត្ត ឬការធ្វើឲ្យរងគ្រោះបន្ថែមទៀត នៅក្នុងនីតិវិធីតុលាការឡើយ។

(ii) បន្តផ្ដល់ការគាំទ្រផ្នែកសង្គមកិច្ច សុខាភិបាល ចិត្តសាស្ត្រ និងការគាំទ្រចាំបាច់ផ្សេងៗទៀតដល់ជនរងគ្រោះដោយសារការជួញដូរ និងគ្រួសាររបស់ពួកគេ ជាពិសេសស្ត្រីមានផ្ទៃពោះ ជនពិការ និងអ្នកដែលឆ្លងជំងឺកាមរោគនិងមេរោគ និង/ឬជំងឺអេដស៍ផង។

(iii) ជនរងគ្រោះដោយសារការជួញដូរ ពុំត្រូវទទួលរងការរើសអើងពីសង្គម ឬការធ្វើឲ្យអាម៉ាស់ដោយសារស្លាកស្នាមផ្លូវចិត្តនោះឡើយ។

(iv) កុមាររងគ្រោះដែលមានវ័យត្រូវចូលសាលា ត្រូវបានធានានូវឱកាសទទួលការអប់រំដ៏សមស្រប។

**ប្រការ១៨៖**

ដើម្បីឱ្យការធ្វើសមាហរណកម្មមានប្រសិទ្ធភាព រដ្ឋភាគីត្រូវផ្ដល់នូវកម្មវិធីបណ្ដុះបណ្ដាល ជាឯកតោភាគី ឬទ្វេភាគី ដូចតទៅ៖

ក. កម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយសារការជួញដូរ ដើម្បីបង្កើនឱកាសមធ្យោបាយចិញ្ចឹមជីវិតបន្ថែម។

ខ. កម្មវិធីបណ្ដុះបណ្ដាលសម្រាប់អ្នកធ្វើការជាមួយជនរងគ្រោះដោយសារការជួញដូរស្ដីអំពីការអភិវឌ្ឍន៍កុមារ សិទ្ធិកុមារ និងបញ្ហាយេនឌ័រទាក់ទងនឹងកុមារដោយយោងតាមបទដ្ឋានអន្តរជាតិ។

គ. កម្មវិធីបណ្ដុះបណ្ដាលស្ដីពីការតាមដាន និងត្រួតពិនិត្យសម្រាប់អ្នកផ្ដល់សេវាដល់ជនរងគ្រោះ។

## ផ្នែកទី៨: ក្រុមការងារចំរុះ

**ប្រការ១៩៖**

ក. រដ្ឋភាគី ត្រូវបង្កើតក្រុមការងារចំរុះមួយ។

ខ. ក្រុមការងាចំរុះនេះ មានសមាសភាពជាអ្នកតំណាងមានសមត្ថកិច្ចនៃរដ្ឋភាគី ទាំងពីរ។

គ. ក្រុមការងារចំរុះ នឹងត្រូវជួបប្រជុំនៅពេលមានតម្រូវការចាំបាច់។ កាលបរិច្ឆេទ និងទីកន្លែងប្រជុំនឹងត្រូវសម្រេចដោយមានការឯកភាពពីរដ្ឋភាគីទាំងពីរ។

ឃ. ក្រុមការងារចំរុះ មានភារកិច្ចដូចតទៅ៖

(i) បង្កើតផែនការសកម្មភាពរួម

S. Khoungt

(ii) ពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពរួមរៀងរាល់ឆ្នាំ និងធ្វើរបាយការណ៍ជូនគណៈកម្មការរួម សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងថៃ និងកម្ពុជា នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការនេះ។

(iii) ផ្តួចផ្តើមបង្កើតយុទ្ធសាស្ត្រ គោលការណ៍អនុវត្តន៍ និងក្របខណ្ឌចាំបាច់ ផ្សេងៗទៀត ដើម្បីអនុវត្តអនុស្សរណៈនេះ។

(iv) លើកអនុសាសន៍សំដៅធ្វើឲ្យមានការរីកចម្រើន ដល់កិច្ចសហប្រតិបត្តិការទៅវិញទៅមក ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។

(v) ជំរុញការចូលរួម និងសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជន នៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសកុមារ និងស្ត្រី ការកេងប្រវ័ញ្ចផ្លូវភេទនិងកម្លាំងពលកម្ម និងពលកម្មដោយបង្ខំ។

(vi) ពិនិត្យឡើងវិញនូវការអនុវត្តន៍អនុស្សរណៈ នេះរៀងរាល់០៣ឆ្នាំម្តង។

## ផ្នែកទី៩: អវសានប្បញ្ញត្តិ

**ប្រការ២០៖**

រដ្ឋភាគីត្រូវខិតខំដោះស្រាយវិវាទទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុស្សរណៈនេះតាមរយៈការចរចា។

អនុស្សរណៈនៃការយោគយល់នេះត្រូវចូលជាធរមានចាប់ពីកាលបរិច្ឆេទដែលរដ្ឋភាគីទាំងពីរបានចុះហត្ថលេខា។

**ប្រការ២១៖**

រដ្ឋភាគីនីមួយៗ អាចបញ្ឈប់ការអនុវត្តអនុស្សរណៈនៃការយោគយល់នេះបានគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋភាគីម្ខាងទៀតតាមរយៈការទូត ហើយការជូនដំណឹងនេះនឹងមានប្រសិទ្ធភាពអនុវត្តក្រោយរយៈពេល៦ខែ គិតចាប់ពីថ្ងៃដែលរដ្ឋភាគីម្ខាងទៀតបានទទួលលិខិតជូនដំណឹង។

**ប្រការ២២៖**

អនុស្សរណៈ នៃការយោគយល់នេះអាចធ្វើវិសោធនកម្មបាន ដោយមានការយល់ព្រមពីរាជ រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២៣៖**

អនុស្សរណៈនៃការយោគយល់គ្នានេះ ត្រូវជំនួសអនុស្សរណៈនៃការយោគយល់គ្នាដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខា នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៣ ដែលត្រូវឈប់អនុវត្តនៅពេលអនុស្សរណៈនេះចូលជាធរមាន។

សកម្មភាពឬវិធានការសហប្រតិបត្តិការមួយចំនួនដែលបានអនុវត្តក្រោមអនុស្សរណៈនៃការយោគយល់គ្នាដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខា នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៣ នៅធរមាននៅឡើយ ហើយរាក់ជាសកម្មភាព និងវិធានការសហប្រតិបត្តិការ ដែលអនុវត្តនៅក្នុងអនុស្សរណៈនៃការយោគយល់គ្នានេះផងដែរ។

S. Khengrit.

ដើម្បីជាសក្ខីភាព ហត្ថលេខីដែលបានទទួលការអនុញ្ញាតត្រឹមត្រូវពីរាជរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើអនុស្សរណៈនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៤ ជាលាយលក្ខណ៍អក្សរ ជាពីរច្បាប់ ជាភាសាថៃ ភាសាខ្មែរ និងអង់គ្លេស អត្ថបទនីមួយៗមានតម្លៃស្មើៗគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល។

**តំណាងរាជរដ្ឋាភិបាល**
**នៃព្រះរាជាណាចក្រថៃ**

ឯកឧត្តមនាយឧត្តមសេនីយ៍ **អាឌុល សានស៊ីងកែវ**
**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍សង្គម**
**និងសន្តិសុខមនុស្ស**

**តំណាងរាជរដ្ឋាភិបាល**
**នៃព្រះរាជាណាចក្រកម្ពុជា**

**ឯកឧត្តម អុិត សំហេង**
**រដ្ឋមន្ត្រីក្រសួងការងារ**
**និងបណ្តុះបណ្តាលវិជ្ជាជីវៈ**